# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ :** ៤៣ ប្រក.បក

# ប្រកាស
## ស្តីពី
## ការផ្ទេរក្របខណ្ឌមន្ត្រីរាជការ

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ២៣៦៣ មស.គ្ររ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងមុខងារសាធារណៈ

## សម្រេច

**ប្រការ១.-**

ផ្ទេរក្របខណ្ឌមន្ត្រីរាជការចំនួន ១០រូប ដូចមានរាយនាមខាងក្រោម៖

១. លោក **លីម ខួនហួត** ពីទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌក្រសួងធម្មការ និងសាសនា

២. លោក **អ៊ិត រតនៈ** ពីទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

៣. លោក **លីម ឈុនលាង** ពីទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

| | | |
|---|---|---|
| ៤. លោក | **ស៊ីយ៉ុន ស្ថាពរ** | ពីទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា |
| ៥. លោក | **ឯម តារា** | ពីទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា |
| ៦. លោក | **អ៊ុំ ទិរៈ** | ពីទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា |
| ៧. លោក | **លី វណ្ណៈ** | ពីទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ |
| ៨. លោក | **ប្រាជ្ញ ឡើន** | ពីទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៩. កញ្ញា | **ទន សុគន្ធា** | ពីទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ១០. លោក | **ហុក សុខហួរ** | ពីទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យទៅបម្រើការងារក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ។ |

**ប្រការ២.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានផលិតកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ប្រធាននាយកដ្ឋានរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងបរិស្ថាន និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**កន្លែងទទួល :**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- ក្រសួងធម្មការ និងសាសនា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិ